ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ២២៧ ប្រក.កសក

# ប្រកាស
## ស្តីពីបែបបទនៃការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ក្នុងស្រុក

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម. រុក្ខាប្រមាញ់ និង នេសាទ និង ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និង ស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង មជ្ឈមណ្ឌលព័ត៌មាន និង ឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

## សម្រេច

**ប្រការ ១ :** ប្រកាសនេះមានគោលបំណងកំណត់បែបបទនៃការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វក្នុងស្រុក ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនូវជំងឺសត្វ ការពារសុខភាពសត្វ និង សំដៅការពារដល់សុខភាពសាធារណៈ ដោយអនុវត្តវិធានបសុពេទ្យលើការនាំយក ការដឹកជញ្ជូនសត្វ ផលិតផលមានដើមកំណើតពីសត្វ មធ្យោបាយដឹកជញ្ជូន ឧបករណ៍ចិញ្ចឹម ឧបករណ៍ដាក់សត្វ សម្ភារៈវេចខ្ចប់ផលិតផលមានដើមកំណើតពីសត្វ តាមទីផ្សារសាធារណៈ ឃ្លាំងស្តុក រោងចក្រ សហគ្រាស កសិដ្ឋាន កន្លែងចិញ្ចឹមសត្វ ស្ថានីយ៍ចត្តាឡីស័កសត្វ ។

**ប្រការ ២ :** ការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វក្នុងរង្វង់ខេត្ត ក្រុង លើកលែងមច្ឆជាតិ និង ផលផលិតផលជលផល ជាសមត្ថកិច្ចរបស់ការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្ត ក្រុងសាមី ។ នាយកដ្ឋានផលិតកម្ម និង បសុព្យាបាលមានសមត្ថកិច្ចចុះត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ដោយអនុវត្តនីវិធានបសុពេទ្យទូទាំងប្រទេសតាមការចាំបាច់ ។

**ប្រការ ៣ :** ការនាំយក ឬ ការដឹកជញ្ជូនសត្វ ផលិតផលមានដើមកំណើតពីសត្វ តាមគ្រប់មធ្យោបាយ និង តាមទីផ្សារសាធារណៈ ឃ្លាំងស្តុក រោងចក្រ សហគ្រាស កសិដ្ឋាន កន្លែងចិញ្ចឹមសត្វ ស្ថានីយ៍ចត្តាឡីស័កសត្វ ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម ÷

**ក- សត្វគ្រប់ប្រភេទ**

- ហាមនាំយក ឬ ដឹកជញ្ជូនសត្វមានរបួស និង មានការឈឺចុកចាប់ដោយប្រការផ្សេងៗ
- ហាមនាំយក ឬ ដឹកជញ្ជូនសត្វជើមជិតកើតកូន សត្វកើតកូន៤៨ (សែសិបប្រាំបី) ម៉ោង មុនពេលដឹកជញ្ជូន និង កូនទើបកើតថ្មីដែលផ្ចិតមិនទាន់ជាសះស្បើយ
- ត្រូវផ្តល់ទឹកដោះ ឬ បំបៅដោះប្រមាណ១២(ដប់ពីរ) ម៉ោងម្តង ចំពោះកូនសត្វដែលមិនបានយកមេទៅតាមជាមួយ
- ត្រូវមានសុខភាពល្អ និង ត្រូវចាក់វ៉ាក់សាំងការពារជំងឺសត្វទៅតាមការកំណត់របស់សមត្ថកិច្ចផលិតកម្ម និង បសុព្យាបាល
- ត្រូវដឹកជញ្ជូន មាន់ ទា និង បក្សា បក្សីដទៃទៀត ដាក់ក្នុងទ្រុង ឬ ដាល
- ហាមចងជើងព្យួរភ្ជាប់នឹងមធ្យោបាយដឹកជញ្ជូន
- មិនត្រូវអនុញ្ញាតឱ្យដឹកជញ្ជូនសត្វ ក្នុងករណីដែលការដឹកជញ្ជូនអាចបង្កឱ្យមានរបួស ឬ មានការឈឺចុកចាប់ដល់សត្វទាំងនោះ
- ត្រូវដាក់តាមអាយុ តាមប្រភេទសត្វ និង ចំណុះផ្ទៃក្រឡាឱ្យបានសមស្របដើម្បីឱ្យសត្វឈរ ដេកតាមលក្ខណៈធម្មជាតិ និង ដាក់ឱ្យនៅដាច់ដោយឡែកពីមនុស្ស

- ត្រូវរកកន្លែងឱ្យសត្វសម្រាក ផ្តល់ចំណី ទឹកនៅតាមដងផ្លូវ ក្នុងករណីការនាំយក ការដឹកជញ្ជូនលើសពី ២៤ (ម្ភៃបួន) ម៉ោង ។ ទីកន្លែងសម្រាប់ឱ្យសត្វសម្រាកត្រូវមានការអនុញ្ញាតពីបសុពេទ្យមានសមត្ថកិច្ច
- ហាមប្រើបសុឱសថឱ្យសត្វរម្ងាប់អារម្មណ៍ ឬ ឱ្យដេក វៀរលែងតែមានព្រឹត្តិការណ៍ ឬ ករណីពិសេសដោយមានការពិនិត្យផ្ទាល់ពីបសុពេទ្យមានសមត្ថកិច្ច
- ត្រូវប្រមូលសត្វងាប់ កម្រាលឱ្យសត្វដេក កាកសំណល់ផ្សេងៗ យកចេញឱ្យបានឆាប់រហ័សបំផុត និងត្រូវអនុវត្តវិធានបសុពេទ្យជាបន្ទាន់ ។

**ខ- ផលិតផលមានដើមកំណើតពីសត្វ**

- ត្រូវរុំ ឬ វេចខ្ចប់ផលិតផលមានដើមកំណើតពីសត្វ ឱ្យមានអនាម័យ និង មានសុវត្ថិភាព
- ត្រូវដាក់ក្នុងធុងបិទជិត មិនឱ្យបំណែកស្បែក ឈាម ទឹក ជ្រះ ស្រក់ តាមផ្លូវដឹកជញ្ជូនចំពោះស្បែកស្រស់
- ត្រូវវេចខ្ចប់ឱ្យសមស្រប និង ធានាអនាម័យចំពោះស្បែកស្ងួត
- ត្រូវដាក់ក្នុងថ្លា ឬ ជាល ឬ កញ្ជោរ ។ល។ ចំពោះស៊ុតបក្សីគ្រប់ប្រភេទ ។

**គ-មធ្យោបាយដឹកជញ្ជូន ឧបករណ៍ចិញ្ចឹម ឧបករណ៍ដាក់សត្វ សម្ភារៈវេចខ្ចប់ផលិតផលមានដើមកំណើតពីសត្វ**

- ត្រូវរៀបចំឱ្យមានផ្ទៃរាបស្មើជិតល្អ មិនឱ្យកាកសំណល់ជ្រះ ជ្រាប ស្រក់ទឹក ធានាគុណភាព សុវត្ថិភាព មានភាពរឹងមាំឱ្យបានសមស្រប ធានាអនាម័យ ខ្យល់ចេញ ចូលគ្រប់គ្រាន់ និង មានលក្ខណៈងាយស្រួលក្នុងការបោសសម្អាត លាង និង បាញ់ថ្នាំសម្លាប់មេរោគទៅលើមធ្យោបាយដឹកជញ្ជូនសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ដូចមានរូបភាពដែលជាឧបសម្ព័ន្ធភ្ជាប់ប្រកាសនេះ
- ត្រូវដាក់សញ្ញាសម្គាល់ដែលមានសញ្ញាបញ្ជាក់អំពីវត្តមាន "សត្វរស់" លើមធ្យោបាយដឹកជញ្ជូន សម្រាប់ដឹកជញ្ជូនសត្វ
- ត្រូវលាងសម្អាតបាញ់ថ្នាំសម្លាប់មេរោគលើមធ្យោបាយដឹកជញ្ជូន ឧបករណ៍ចិញ្ចឹម ឧបករណ៍ដាក់សត្វ សម្ភារៈវេចខ្ចប់ផលិតផលមានដើមកំណើតពីសត្វ មុន និង ក្រោយពេលដឹកជញ្ជូន ។

**ឃ- ឃ្លាំងស្តុក រោងចក្រ សហគ្រាស កសិដ្ឋាន កន្លែងចិញ្ចឹមសត្វ ស្ថានីយ៍ចត្តាឡីស័កសត្វ**

- ត្រូវសង្កេតតាមដាន ស្រាវជ្រាវ ត្រួតពិនិត្យសុខភាពសត្វ អនាម័យផលិតផលមានដើមកំណើតពីសត្វតាមទីកន្លែងជាប្រចាំ
- ត្រូវអនុវត្តវិធានជីវសុវត្ថិភាពជាប្រចាំ នៅតាមទីកន្លែង និង រាល់សកម្មភាពចេញ ចូល
- ត្រូវអនុវត្តបាញ់ថ្នាំសម្លាប់មេរោគឱ្យបានពីរដងក្នុងមួយខែតាមទីកន្លែងនីមួយៗ ។

**ប្រការ ៤ :** រូបវន្តបុគ្គល ឬ នីតិបុគ្គលមុនធ្វើការនាំយក ឬ ដឹកជញ្ជូនទំនិញដែលជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ក្នុងរង្វង់ខេត្ត ក្រុង ឬ ទៅខេត្ត ក្រុងណាមួយ ត្រូវសុំការត្រួតពិនិត្យ

នៅការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្ត ក្រុងសាមី ដោយភ្ជាប់មកជាមួយ នូវលិខិតអនុញ្ញាតឱ្យប្រមូលទិញសត្វ ឬ ផលិតផលមានដើមកំណើតពីសត្វ ភិនសត្វ ឬ អត្តសញ្ញាណប័ណ្ណសត្វ ឬ ស្លាកបសុពេទ្យសម្រាប់សម្គាល់ផលិតផលមានដើមកំណើតពីសត្វ លើកលែង សត្វព្រៃ និង ផលិតផលសត្វព្រៃ មិនតម្រូវឱ្យភ្ជាប់នូវឯកសារទាំងនេះ ប៉ុន្តែត្រូវភ្ជាប់នូវឯកសារពាក់ព័ន្ធដទៃទៀត ។

**ប្រការ ៥** : មុនពេលចេញវិញ្ញាបនបត្រអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ មន្ត្រីបសុពេទ្យមានសមត្ថកិច្ចត្រូវ ÷

- កំណត់ទីកន្លែងសមស្របតាមលក្ខណៈបច្ចេកទេសដើម្បីធ្វើការត្រួតពិនិត្យអនាម័យ
- ស្រង់ព័ត៌មាន និង អង្កេតតាមដានប្រវត្តិប្រភពដើមរបស់សត្វ ឬ ផលិតផលមានដើមកំណើតពីសត្វ
- ត្រួតពិនិត្យសុខភាព និង ស្ថានភាពទូទៅរបស់សត្វ ឬ ផលិតផលមានដើមកំណើតពីសត្វ
- ត្រួតពិនិត្យភិនសត្វ ឬ អត្តសញ្ញាណប័ណ្ណសត្វ ឬ ស្លាកបសុពេទ្យសម្រាប់សម្គាល់ផលិតផលមានដើមកំណើតពីសត្វ និង ឯកសារពាក់ព័ន្ធដទៃទៀត
- ពិនិត្យអនាម័យ លក្ខខណ្ឌវេចខ្ចប់ ថែរក្សា ផលិតផលមានដើមកំណើតពីសត្វ ។

**ប្រការ ៦** : វិញ្ញាបនបត្រអនាម័យសត្វ ឬ ផលិតផលមានដើមកំណើតពីសត្វ អាចផ្តល់ជូនដល់រូបវន្តបុគ្គល ឬ នីតិបុគ្គល បានក្នុងករណីលទ្ធផលនៃការត្រួតពិនិត្យ ឬ វិភាគលើទំនិញទាំងនោះ តាមលក្ខណៈបច្ចេកទេសបសុពេទ្យ ឃើញថាមានសុខភាពល្អ អនាម័យ លក្ខខណ្ឌវេចខ្ចប់ថែរក្សាត្រឹមត្រូវ និង គ្មានមេរោគបង្កជំងឺឆ្លង ។

**ប្រការ ៧** : ការចេញវិញ្ញាបនបត្រអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ សម្រាប់ដឹកជញ្ជូនក្នុងស្រុក ជាសមត្ថកិច្ចរបស់ការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្ត ក្រុងសាមី ដែលចុះទិដ្ឋាការដោយមន្ទីរកសិកម្ម ។

**ប្រការ ៨** : ការទិញសត្វ ឬ ដឹកជញ្ជូនសត្វជាលក្ខណៈគ្រួសារសម្រាប់យកទៅចិញ្ចឹមធ្វើជាពូជ ឬ បង្កបង្កើនផល មិនធ្វើអាជីវកម្មពីខេត្ត ក្រុងមួយ ទៅខេត្ត ក្រុងមួយ មិនតម្រូវឱ្យមានលិខិតអនុញ្ញាតទិញ ប៉ុន្តែត្រូវមានវិញ្ញាបនបត្រអនាម័យសត្វ ចេញដោយផ្នែកផលិតកម្ម និង បសុព្យាបាលស្រុក ខណ្ឌ ។

**ប្រការ ៩** : រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបានការអនុញ្ញាតដឹកជញ្ជូនសត្វ ឬ ផលិតផលមានដើមកំណើតពីសត្វ ត្រូវបង្កភាពងាយស្រួលដល់មន្ត្រីត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ដើម្បីអនុវត្តនីតិវិធានបសុពេទ្យដូចខាងក្រោម ÷

**ក. កន្លែងចេញដំណើរ ( ដើមទី)**

- ត្រួតពិនិត្យរាល់ឯកសារពាក់ព័ន្ធក្នុងការដឹកជញ្ជូន
- ត្រួតពិនិត្យសុខភាព និង ចំនួនសត្វ
- ត្រួតពិនិត្យអនាម័យ គុណភាព សុវត្ថិភាព និង លក្ខខណ្ឌវេចខ្ចប់ផលិតផលមានដើមកំណើត ពីសត្វ និង បរិមាណ

- ត្រួតពិនិត្យអនាម័យ គុណភាព សុវត្ថិភាព នៃមធ្យោបាយដឹកជញ្ជូន ឧបករណ៍ដាក់សត្វ
- បញ្ជាក់លើឯកសារពាក់ព័ន្ធក្នុងការដឹកជញ្ជូន ។

ក្នុងករណីពិនិត្យឃើញថាសត្វមានសុខភាព ឬ អនាម័យផលិតផលមានដើមកំណើតពីសត្វ និង អនាម័យ គុណភាព សុវត្ថិភាពនៃមធ្យោបាយដឹកជញ្ជូន ឧបករណ៍ដាក់សត្វ មិនប្រក្រតីត្រូវបញ្ឈប់ការដឹកជញ្ជូន នឹងអនុវត្ត វិធានបសុពេទ្យជាបន្ទាន់ ។

**ខ. កន្លែងឆ្លងកាត់ (កណ្តាលទី)**

- ពិនិត្យផ្ទៀងផ្ទាត់រាល់ឯកសារពាក់ព័ន្ធក្នុងការដឹកជញ្ជូន
- ត្រួតពិនិត្យសុខភាព និង ចំនួនសត្វ
- ត្រួតពិនិត្យអនាម័យ គុណភាព សុវត្ថិភាព និង លក្ខខណ្ឌវេចខ្ចប់ផលិតផលមានដើមកំណើត ពីសត្វ និង បរិមាណ
- ត្រួតពិនិត្យអនាម័យ គុណភាព សុវត្ថិភាព នៃមធ្យោបាយដឹកជញ្ជូន ឧបករណ៍ដាក់សត្វ
- បញ្ជាក់លើឯកសារពាក់ព័ន្ធក្នុងការដឹកជញ្ជូន ។

ក្នុងករណីពិនិត្យឃើញថាសត្វមានសុខភាព ឬ អនាម័យផលិតផលមានដើមកំណើតពីសត្វ និង អនាម័យ គុណភាព សុវត្ថិភាពនៃមធ្យោបាយដឹកជញ្ជូន ឧបករណ៍ដាក់សត្វ មិនប្រក្រតីត្រូវបញ្ឈប់ការចលនាបន្តជា បណ្តោះអាសន្ន នឹងអនុវត្តវិធានបសុពេទ្យជាបន្ទាន់ ។

**គ.កន្លែងទៅដល់ (ចុងទី)**

- ពិនិត្យផ្ទៀងផ្ទាត់រាល់ឯកសារពាក់ព័ន្ធក្នុងការដឹកជញ្ជូន
- ត្រួតពិនិត្យសុខភាព និង ចំនួនសត្វ
- ត្រួតពិនិត្យអនាម័យ គុណភាព សុវត្ថិភាព និង លក្ខខណ្ឌវេចខ្ចប់ផលិតផលមានដើមកំណើតពីសត្វ និង បរិមាណ
- ត្រួតពិនិត្យអនាម័យ គុណភាព សុវត្ថិភាព នៃមធ្យោបាយដឹកជញ្ជូន ឧបករណ៍ដាក់សត្វ
- បញ្ជាក់លើឯកសារពាក់ព័ន្ធក្នុងការដឹកជញ្ជូន ។

ចំពោះសត្វគ្រប់ប្រភេទមុន និង ក្រោយពេលដឹកជញ្ជូនមិនត្រូវធ្វើទារុណកម្មឡើយ ។

ក្នុងករណីពិនិត្យឃើញថាសត្វមានសុខភាពមិនប្រក្រតី ត្រូវបញ្ឈប់ការចែកចាយ ឬ ចលនាបន្ត នឹង អនុវត្តវិធានបសុពេទ្យជាបន្ទាន់ ។

**ប្រការ ១០.** ការប្រមូលទិញសត្វ ឬ ផលិតផលមានដើមកំណើតពីសត្វក្នុងរង្វង់ខេត្ត ក្រុង លើកលែងមច្ឆជាតិ ផលផលិតផលជលផល សត្វព្រៃ និង ផលិតផលសត្វព្រៃ ត្រូវមានលិខិតអនុញ្ញាតឱ្យប្រមូលទិញ ចេញ ដោយការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្ត ក្រុងសាមី និងចុះទិដ្ឋាការដោយមន្ទីរកសិកម្ម ។

ការប្រមូលទិញសត្វ ឬ ផលិតផលមានដើមកំណើតពីសត្វ ឆ្លងពីខេត្ត ក្រុងមួយ ទៅខេត្ត ក្រុងមួយ លើកលែងមច្ឆជាតិ ផលផលិតផលជលផល សត្វព្រៃ និង ផលិតផលសត្វព្រៃ ត្រូវមានលិខិតអនុញ្ញាតឱ្យប្រមូលទិញ ចេញដោយនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ។

**ប្រការ ១១ :** ប្រកាស ឬ សេចក្ដីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១២ :** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល គ្រប់ប្រធានអង្គភាពដែលមានការពាក់ព័ន្ធ ប្រធានមន្ទីរកសិកម្មខេត្ត ក្រុង ត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៨

រដ្ឋមន្ត្រី

ចាន់ សារុន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ១២
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី..........ភ្ជាប់ប្រកាសលេខ............ប្រក.កសក ចុះថ្ងៃទី......ខែ.......ឆ្នាំ ២០០៨

ស្តីពីមធ្យោបាយដឹកជញ្ជូនគោ-ក្របីដោយរថយន្ត



រថយន្តដឹក គោ-ក្របី មើលពីក្រោយ



រថយន្តដឹក គោ-ក្របី មើលពីចំហៀង

**ឧបសម្ព័ន្ធទី...........ភ្ជាប់ប្រកាសលេខ............ប្រក.កសក ចុះថ្ងៃទី.....ខែ......ឆ្នាំ ២០០៨**

**ស្តីពីមធ្យោបាយដឹកជញ្ជូន ពពែ-ចៀម ដោយរថយន្ត**



រថយន្តដឹក ពពែ-ចៀម មើលពីចំហៀង



រថយន្តដឹក ពពែ-ចៀម មើលពីចំហៀង

ឧបសម្ព័ន្ធទី..........ភ្ជាប់ប្រកាសលេខ...........ប្រក.កសក ចុះថ្ងៃទី.....ខែ.......ឆ្នាំ ២០០៨
ស្តីពីមធ្យោបាយដឹកជញ្ជូនជ្រូកដោយរថយន្ត



រថយន្តដឹកជ្រូកមើលពីក្រោយ



ជុចដាក់ជ្រូក អំពីដែក



រថយន្តដឹកជ្រូកដាក់ក្នុងជុច



រថយន្តដឹកជ្រូកមើលពីចំហៀង



រថយន្តដឹកជ្រូក (លាត)

ឧបសម្ព័ន្ធទី...........ភ្ជាប់ប្រកាសលេខ............ប្រក.កសក ចុះថ្ងៃទី.....ខែ......ឆ្នាំ ២០០៨

ស្តីពីមធ្យោបាយដឹកជញ្ជូនជ្រូកដោយរទេះក្រយានយន្ត



ជុចដាក់ជ្រូក



ជុចជ្រូកមើលពីចំហៀង



រទេះក្រយានយន្តដឹកជ្រូកដាក់ក្នុងជុច

ឧបសម្ព័ន្ធទី..........ភ្ជាប់ប្រកាសលេខ............ប្រក.កសក ចុះថ្ងៃទី......ខែ.......ឆ្នាំ ២០០៨

**ស្តីពីមធ្យោបាយដឹកជញ្ជូនបក្សីដោយរថយន្ត**




ទ្រុងដាក់បក្សី



រថយន្តដឹក បក្សី មើលពីចំហៀង



រថយន្តដឹក បក្សី មើលពីក្រោយ

ឧបសម្ព័ន្ធទី...........ភ្ជាប់ប្រកាសលេខ............ប្រក.កសក ចុះថ្ងៃទី.....ខែ......ឆ្នាំ ២០០៨

## ស្តីពីមធ្យោបាយដឹកជញ្ជូនបក្សីដោយទោចក្រយានយន្ត



ទោចក្រយានយន្តដឹកបក្សីមើលពីក្រោយ



ទោចក្រយានយន្តដឹកបក្សីមើលពីចំហៀង